ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ : ១៤០/១៦ ក.ណ.ហ

# កំណត់ហេតុ
## វគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ
## ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប
## ពីថ្ងៃទី១៣ ដល់ទី១៦ ខែកញ្ញា ឆ្នាំ២០១៦
## នៅក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែកញ្ញា ពីថ្ងៃទីដប់បី ដល់ទីដប់ប្រាំមួយ នៅទីស្តីការក្រសួងមហាផ្ទៃ មានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលរៀបចំដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ។

### ក. អំពីវគ្គបណ្តុះបណ្តាល

គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះគឺ បណ្តុះបណ្តាលគ្រូបង្គោលដើម្បីពួកគាត់យកទៅបណ្តុះបណ្តាលបន្តដល់ប្រតិបត្តិករទាំងឡាយ ឲ្យបានយល់ដឹងកាន់តែច្បាស់អំពីនីតិវិធី និងបែបបទនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងដំណាក់កាលនៃការបញ្ជូនជនរងគ្រោះពីកន្លែងមួយទៅកន្លែងមួយរហូតដល់កន្លែងផ្តល់សេវាណាមួយដែលសមស្របសម្រាប់ពួកគាត់ ។ វគ្គបណ្តុះបណ្តាលនេះធ្វើនៅរាជធានីភ្នំពេញ ដែលជាវគ្គបណ្តុះបណ្តាលដំបូង ហើយក៏ជាវគ្គសាកល្បងផងដែរ ដើម្បីធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីចំណុចខ្វះខាត ដើម្បីធ្វើការកែសម្រួលឲ្យបានល្អប្រសើរ សម្រាប់យកទៅបណ្តុះបណ្តាលនៅតាមបណ្តាខេត្តបន្តទៀត ។

សមាសភាពចូលរួមវគ្គបណ្តុះបណ្តាលមានចំនួន ៣៥នាក់(ស្រី ៨នាក់) ដែលក្នុងនោះមានៈ គ្រូឧទ្ទេសចំនួន ៨នាក់(ស្រី ២នាក់)(គ្រូឧទ្ទេសសរុប ៩នាក់ អវត្តមានម្នាក់មកពីក្រសួងការបរទេស) និងសិក្ខាកាមជាគ្រូបង្គោលចំនួន ២៧នាក់(ស្រី ៦នាក់) មកពី ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងការពារជាតិ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានអន្តោប្រវេសន៍ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ស្ថានទូតសហរដ្ឋអាមេរិក អង្គការ IOM, WINROCK, UN-ACT, Cambodia ACTs និង APLE ។

### ខ. ដំណើរការនៃវគ្គបណ្តុះបណ្តាល

Pre-Test :

ការបណ្តុះបណ្តាលចាប់ផ្តើមដំបូងដោយ ការធ្វើសំនួរសាកល្បងមុនការបង្រៀន (Pre-Test) ដើម្បីឲ្យដឹងពីការយល់ដឹងរបស់សិក្ខាកាមមុនការបង្រៀន សម្រាប់ធ្វើការវាយតម្លៃនៅចុងបញ្ចប់នៃការបណ្តុះបណ្តាល ។ Pre-Test ត្រូវបានធ្វើជាលក្ខណៈក្រដាសសំនួរ ឲ្យសិក្ខាកាមបំពេញចម្លើយ និងជ្រើសរើសចម្លើយ ។

**មេរៀន ៖ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

(ដោយលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ)

- ការចែកឯកសារគតិយុត្តិគ្រប់ច្បាប់ជូនសិក្ខាកាមមិនអាចទៅរួច ព្រោះឯកសារមានច្រើន និងខ្លះជាសៀវភៅ ។

**មេរៀន ៖ ស្ថានភាពទូទៅនៃការជួញដូរមនុស្ស**

(ដោយលោក **លឹម ទិត្យ** មកពី UN-ACT)

- និយមន័យទេសន្តរប្រវេសន៍ នៅមិនច្បាស់ ត្រូវការពិភាក្សាសម្រេច
- ចង់ឲ្យប្រៀបធៀបច្រើនអំពីទិន្នន័យអន្តរជាតិ និងទិន្នន័យកម្ពុជា
- គួរ classify កត្តាជំរុញ និងអូសទាញ, កត្តាបុគ្គល និងសង្គម
- ត្រូវបញ្ជាក់ឲ្យច្បាស់ពាក្យ "មធ្យោបាយ" គឺល្បិចកល (មិនមែនមធ្យោបាយដឹកជញ្ជូនទេ)
- គួរបញ្ជាក់ពីគោលនយោបាយ និងដៃគូ

**មេរៀន ៖ ផែនការ យុទ្ធសាស្ត្រ យន្តការ លទ្ធផល ភាពប្រឈម និងទិសដៅរបស់ គ.ជ.ប.ជ**

(ដោយលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ)

- តារាងរចនាសម្ព័ន្ធខ្វះការិយាល័យស្រាវជ្រាវព័ត៌មាន ។
- ខ្វះទិសដៅ ១២ធ្នូ ២០១៦ ។

**មេរៀន ៖ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ពាក់ព័ន្ធ ការអនុវត្តច្បាប់ជាតិ និងច្បាប់នៅប្រទេសពាក់ព័ន្ធ**

(ដោយឯកឧត្តម **សុច សុផាន់ណារ៉ា** មកពីក្រសួងយុត្តិធម៌)

- ត្រូវរកចំណុចគន្លឹះ ដូចជាទោសពាក់ព័ន្ធអំពើជួញដូរមនុស្សប្រព្រឹត្តចំពោះនីតិជន អនីតិជន ទោសធ្ងន់ ទោសស្រាល ដើម្បីឲ្យជនល្មើសបានដឹង កុំឲ្យចេះតែហ៊ាន ។
- អំពីប្រវត្តិបង្កើតច្បាប់ គួរតែសង្ខេបត្រឹមថ្ងៃបង្កើត និងថ្ងៃអនុម័តចុងក្រោយ ។
- គួរបន្ថែមច្បាប់ក្រមព្រហ្មទណ្ឌពាក់ព័ន្ធ ។

**មេរៀន ៖ កិច្ចសហប្រតិបត្តិការក្នុងការការពារ និងជួយសង្គ្រោះជនរងគ្រោះ**

(គ្រូឧទ្ទេសមកពីក្រសួងការបរទេស អវត្តមាន)

**មេរៀន ៖ គម្រោងជំនួយវិលត្រលប់ និងមាតុភូមិនិវត្តន៍ដល់ជនរងគ្រោះដោយសារការជួញដូរ និងពលករដែលងាយរងគ្រោះ**

(ដោយលោក **នុត សំអុល** មកពីអង្គការ IOM)

- IOMកម្ពុជា បង្កើតក្នុងឆ្នាំ២០១១ គាំទ្រដោយសហរដ្ឋអាមេរិក ។
- IOM បានបានស្រង់ទិន្នន័យជនរងគ្រោះពីឆ្នាំ២០១១ដល់២០១៥ (មិនទាន់មាន២០១៦) ។
- IOM មិនមានមូលនិធិសម្រាប់បញ្ជូនទៅសហគមន៍ទេ តែអាចបញ្ជូនទៅអង្គការដៃគូដែល មានមណ្ឌល ដោយមានមេភូមិ មេឃុំ និងសមត្ថកិច្ចដឹងៗ ។
- IOM មិនមានមណ្ឌលទេ តែមានថវិកាស្ងួចស្តើងសម្រាប់ការធ្វើមាតុភូមិនិវត្តន៍ ។
- នៅខេត្តបន្ទាយមានជ័យ មានអង្គការពីរធ្វើការពាក់ព័ន្ធនឹងជនរងគ្រោះគឺ Samaritan's Pures និង IOM ។

- បានចែករំលែកបទពិសោធន៍ក្នុងការជួយជនរងគ្រោះនៅក្រៅប្រទេស និងការបញ្ជូនវិលត្រលប់ហូតដល់កន្លែងផ្ដល់សេវា ។

មេរៀន ៖ ការកំណត់រកជាតុផ្សំ នៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

(ដោយឧត្តមសេនីយ៍ត្រី គឹម ភាព មកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស)

មេរៀន ៖ លក្ខណៈសម្រាប់សម្គាល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

(ដោយឧត្តមសេនីយ៍ត្រី គឹម ភាព មកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស)

មេរៀន ៖ តួនាទីមន្ត្រីសង្គមកិច្ច ក្នុងការការពារ

(ដោយលោកស្រី កែវ ម៉ាលី មកពីក្រសួងសង្គមកិច្ច)

- មន្ត្រីសង្គមកិច្ចតាមបណ្ដាលស្រុក ស្រុកខ្លះមាន១នាក់ ស្រុកខ្លះគ្មានតែម្ដង ។

មេរៀន ៖ ក្រមសីលធម៌ក្នុងការសម្ភាសន៍

(ដោយលោកស្រី កែវ ម៉ាលី មកពីក្រសួងសង្គមកិច្ច)

មេរៀន ៖ សេវាដែលត្រូវផ្ដល់ដល់ជនរងគ្រោះ សេវាសង្គ្រោះបន្ទាន់ និងសេវាជាយុទ្ធសាស្ត្រតាមតម្រូវការ និងសំណូមពរ

(ដោយលោកស្រី កែវ ម៉ាលី មកពីក្រសួងសង្គមកិច្ច)

**សកម្មភាព បែងចែកក្រុមពិភាក្សា៖**

ជាបន្តសិក្ខាកាមត្រូវបានបែងចែកជា ៣ក្រុម ដើម្បីធ្វើការពិភាក្សាលើសំនួរចំនួន ២គឺ៖

១/- ចូរនិយាយអំពី វិធីសាស្ត្រក្នុងការបង្រៀន?

២/- ចូរនិយាយអំពី នីតិវិធីក្នុងការសម្ភាសន៍ជនរងគ្រោះ?

ក្រុមនីមួយៗត្រូវសរសេរចម្លើយនៅលើផ្ទាំងក្រដាសធំ(flipchart) រួចឡើងធ្វើបទបង្ហាញចម្លើយ និងពិភាក្សា។

មេរៀន ៖ សេវាគាំទ្រជនរងគ្រោះ ដោយក្រសួងកិច្ចការនារី

(ដោយលោក ទេព ស៊ីមន មកពីក្រសួងកិច្ចការនារី)

មេរៀន ៖ នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ និងតួនាទីភារកិច្ចរបស់អ្នកពាក់ព័ន្ធ

(ដោយឧត្តមសេនីយ៍ទោ ជីវ ផល្លី មកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស)

មេរៀន ៖ របៀបសម្ភាសន៍ និងការបំពេញបែបបទនៃការសម្ភាសន៍ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ

(ដោយឧត្តមសេនីយ៍ទោ ជីវ ផល្លី មកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស)

- បានបង្រៀនអំពីទម្រង់សម្ភាសន៍ហ័ស និងទម្រង់សម្ភាសន៍លម្អិត ។

**សកម្មភាព សិក្សាករណីដោយដើរតួ៖**

សិក្ខាកាមត្រូវបានបែងចែកជា ៤ក្រុម ក្នុងមួយក្រុមមាន៤ទៅ៦នាក់ មានរយៈពេល ១ម៉ោង ។ ករណីសិក្សានេះគឺក្នុងមួយក្រុម មានម្នាក់ដើរតួជាជនរងគ្រោះ និងអ្នកផ្សេងទៀតដើរតួជាអ្នកសម្ភាសន៍ ដោយធ្វើការអនុវត្តសម្ភាសន៍តាមតាមទម្រង់ដែលបានបង្រៀនរួចហើយ ។ បន្ទាប់មកក្រុមនីមួយៗឡើងធ្វើបទបង្ហាញអំពីលទ្ធផលរបស់ខ្លួន ដោយមានការណែនាំ និងកែតម្រូវពីគ្រូឧទ្ទេស ។

**សកម្មភាព សិក្សាករណីដោយសម្ភាសន៍ជាមួយជនរងគ្រោះពិតប្រាកដ៖**
សិក្ខាកាមត្រូវបានបែងចែកជា ៣ក្រុម ក្នុងមួយក្រុម៤ទៅ៦នាក់ ដើម្បីអនុវត្តការសម្ភាសន៍ជាមួយនឹងជនរងគ្រោះពិតប្រាកដ ចំនួន ៣នាក់ ដែលបានបញ្ជូនមកដោយអង្គការ CCPCR ដោយមួយក្រុមត្រូវសម្ភាសន៍ជនរងគ្រោះម្នាក់ ។ ក្រោយការសម្ភាសន៍ ក្រុមនីមួយៗបានឡើងធ្វើបទបង្ហាញពីលទ្ធផលរបស់ខ្លួន ដោយមានការពិភាក្សា ជជែកវែកញែក និងពន្យល់ពីសិក្ខាកាមដូចគ្នា និងគ្រូឧទ្ទេស បានធ្វើឲ្យសិក្ខាកាមទាំងអស់បានយល់ច្បាស់ និងអាចវិភាគ និងសន្និដ្ឋានថានរណាជាជនរងគ្រោះ មិនមែន ជនរងគ្រោះ និងជនសង្ស័យ ។

## គ. បូកសរុប និងវាយតម្លៃនៃវគ្គបណ្តុះបណ្តាល

ជាកិច្ចបញ្ចប់នៃវគ្គបណ្តុះបណ្តាល លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ បានឲ្យសិក្ខាកាមទាំងអស់បញ្ចេញមតិយោបល់អំពីចំណេះដឹង ដែលទទួលបានពីការបណ្តុះបណ្តាលរយៈពេល៤ថ្ងៃកន្លងមកនេះ ដើម្បីធ្វើការបូកសរុបវាយតម្លៃ ដែលជាលទ្ធផល សិក្ខាកាមទទួលបានដូចខាងក្រោម៖

- ដឹងអំពីច្បាប់ និងបទដ្ឋានគតិយុត្តិមួយចំនួនដែលពាក់ព័ន្ធ ។
- យល់ដឹងច្បាស់អំពីដំណើរការ ក៏ដូចជានីតិវិធី និងបែបបទនៃការកំណត់អត្តសញ្ញាណជងរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- យល់ដឹងច្បាស់អំពីការសម្ភាសន៍ និងការបញ្ជូនជនរងគ្រោះទៅកាន់កន្លែងដែលមានសេវាសមស្របសម្រាប់ពួកគាត់ ។
- បានយល់ដឹងច្រើនអំពីល្បិចកិចកលរបស់ជនខិលខូច ក្នុងការនាំពលករទៅធ្វើការខុសច្បាប់ និងអំពីស្ថានភាពរស់នៅ និងបញ្ហាប្រឈមរបស់ពួកគាត់នៅកន្លែងនោះ ។
- អាចវិភាគ និងស្វែងយល់ថា នរណាជាជនរងគ្រោះពិតប្រាកដ នរណាមិនមែនជាជនរងគ្រោះ និងនរណាអាចជាមេខ្យល់ក្នុងការដឹកនាំជនរងគ្រោះទៅទាំងប្រថុយប្រថាន ។
- បង្កើនចំណេះដឹងអំពីវិធីសាស្ត្រក្នុងការបង្រៀន ។
- ដឹងអំពីសេវារបស់ស្ថាប័នមួយចំនួន និងតួនាទីរបស់ពួកគាត់ ។
- បានទទួលនូវបទពិសោធន៍ជាច្រើនពីការពិភាក្សាគ្នា ដែលមកពីក្រសួងស្ថាប័នផ្សេងៗគ្នា ។
- បានធ្វើឲ្យយើងមានមូលដ្ឋានច្បាស់លាស់ក្នុងការចាត់វិធានការបង្ការ និងទប់ស្កាត់ ។

**ទន្ទឹមនឹងទទួលបានលទ្ធផលខាងលើនេះ ក៏នៅមានចំណុចខ្វះខាតមួយចំនួនផងដែរ ដែលធ្វើឲ្យលទ្ធ ផលដែលទទួលបាននេះមិនទាន់ឆ្លើយតបទៅនឹងការរំពឹងទុក ក្នុងនោះមាន៖**

- ពេលវេលាមិនគ្រប់គ្រាន់ គឺមិនទាន់ឆ្លើយតបសម្រាប់ការបណ្តុះបណ្តាលគ្រូបង្គោល ។
- អវត្តមានគ្រូឧទ្ទេសបានធ្វើឲ្យសិក្ខាកាមមិនបានយល់អំពីការងារពាក់ព័ន្ធមួយចំនួន ។
- មិនទាន់ដឹងច្បាស់អំពីសេវាកម្មរបស់ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធជាច្រើនទៀត ។
- ការបញ្ជូនទៅរកសេវា ត្រូវការសិក្សា និងវិភាគឲ្យបានស៊ីជម្រៅបន្ថែមទៀត ។
- ការរៀបចំមេរៀនមិនទាន់ស៊ីសង្វាក់គ្នា មានចំណុចខ្លះជាន់គ្នា ចំណុចខ្លះពន្យល់មិនទាន់ច្បាស់ និងចំណុចខ្លះមិនទាន់ឯកភាពគ្នា ។

**លោកជំទាវ បានផ្តល់អនុសាសន៍ និងវិធីសាស្ត្របង្រៀនមួយចំនួន សម្រាប់កែលម្អឲ្យប្រសើរឡើងសម្រាប់វគ្គបណ្តុះបណ្តាលក្រោយៗទៀត ដែលរួមមាន៖**

- សិក្ខាកាមត្រូវបន្តការបណ្តុះបណ្តាលបន្ថែមទៀត ដើម្បីឲ្យកាន់តែច្បាស់ និងខ្លាំង ។

- ត្រូវធ្វើយ៉ាងណាឲ្យប្រតិបត្តិករទាំងឡាយមានការយល់ដឹងរួមមួយ អំពីការកំណត់អត្តសញ្ញាណនេះ កុំឲ្យមានការកំណត់ខុសគ្នាដែលនាំឲ្យមានបញ្ហា ។
- ការរៀបចំមេរៀន៖ មេរៀននីមួយៗ ត្រូវមានបញ្ជាក់អំពីគោលដៅ និងគោលបំណង ។ ត្រូវស្វែងរកចំណុចគន្លឹះ ដែលសិក្ខាកាម និងប្រតិបត្តិករចាំបាច់ត្រូវយល់ត្រូវដឹងសម្រាប់ការអនុវត្តឲ្យមានប្រសិទ្ធិភាព ។ បើខ្វះខាត រឺមិនយល់ត្រង់ណា ត្រូវសួរគ្នា ។
- វិធីសាស្ត្របង្រៀន៖
  - ធ្វើបទបង្ហាញតាមការបញ្ចាំងស្លាយ រួចសួរសំនួរចម្លើយ ឬពិភាក្សា
  - បង្ហាញរូបភាព រួចពិភាក្សា
  - សំនួរបំផុសគំនិត
  - បញ្ចាំងភាពយន្តខ្លីៗ រួចដាក់សំនួរពិភាក្សា រួចបង្ហាញចម្លើយ
  - ពិភាក្សាលើករណីសិក្សា
  - ល្បែងកំសាន្តដែលពាក់ព័ន្ធនឹងខ្លឹមសារ
  - ល្បែងដើរតួ (រៀបចំសាច់រឿងសម្តែង)
  - អនុវត្តដាក់ស្តែង រួចពិភាក្សាវាយតម្លៃភាពត្រឹមត្រូវ
  - ចែកក្រុមពិភាក្សា
  - បញ្ចេញគំនិតសសេរលើក្រដាសពណ៌ រួចផ្គុំសាច់រឿង
  - ល្បែងផ្គុំរូបភាព
  - វិធិសាស្ត្រនីមួយៗ ត្រូវតែតាមពេលវេលាកំណត់
  - ត្រូវមានការបូកសរុបពីខ្លឹមសារ ដែលឆ្លើយតបនឹងគោលបំណងមេរៀន ។

ជាកិច្ចបិទវគ្គបណ្តុះបណ្តាល លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ បានថ្លែងអំណរគុណដល់គ្រូឧទ្ទេស និងសិក្ខាកាមជាគ្រូបង្គោលទាំងអស់ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ហើយសង្ឃឹមថាអ្នកទាំងអស់គ្នានឹងអត់ធ្មត់បន្តការសិក្សា ដើម្បីឲ្យគ្រូបង្គោលយើងកាន់តែល្អប្រសើរ ។

វគ្គបណ្តុះបណ្តាលបានប្រព្រឹត្តទៅរយៈពេល ៤ថ្ងៃ (ពីថ្ងៃទី១៣ ដល់ទី១៦ ខែកញ្ញា ឆ្នាំ២០១៦) និងបានបញ្ចប់ដោយទទួលបានលទ្ធផលល្អគួរឲ្យកត់សម្គាល់ ។

ភ្នំពេញ ថ្ងៃទី២២ខែកញ្ញា ឆ្នាំ២០១៦

**អ្នកកត់ត្រា**

ហ៊ុំ. រតនៈ

គោរពជូន លោកជំទាវ

អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៣ ខែ កញ្ញា ឆ្នាំ២០១៦

**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ត្រី គង់_ពុទ្ធិ

ជូ_ប៊ុនអេង

**សមាសភាពចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល**
**ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស**
**ដើម្បីផ្តល់សេវាសមស្រប**
**ពីថ្ងៃទី១៣ ដល់ទី១៦ ខែកញ្ញា ឆ្នាំ២០១៦**
**នៅក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ សរុបចំនួន ៣៥នាក់**

| | | | |
|---|---|---|---|
| - លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការ | ក្រសួងមហាផ្ទៃ |
| - លោកជំទាវ | សាន្ត អរុណ | រដ្ឋលេខាធិការ | ក្រសួងកិច្ចការនារី |
| - លោកជំទាវ | អ៊ុំ សាម៉ុល | អនុរដ្ឋលេខាធិការ | ក្រសួងសុខាភិបាល |
| - លោកជំទាវ | មនោសុទ្ធី ហៃធ | US Embassy | US Embassy |
| - ឯកឧត្តម ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| - ឯកឧត្តម ឧ.ទោ | ស៊ុន វ៉ូ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - លោកជំទាវ ឧ.ទោ | ប៊ុណ្ណ សំខាន់ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - លោកជំទាវ | វ៉ន សិរីលក្ខិណា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - ឧត្តមសេនីយ៍ត្រី | លី តុងហ៊ុយ | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - ឧត្តមសេនីយ៍ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - ឧត្តមសេនីយ៍ត្រី | ស្រី សាមឌី | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - វរសេនីយ៍ឯក | កែវ សុវណ្ណារ៉ា | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - វរៈសេនីយ៍ទោ | សិត ផាត | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - វរៈសេនីយ៍ទោ | សេក ស៊ីវ៉េត | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - លោក | តៃ សុថារ៉េត | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - ឯកឧត្តម | សុច សុផាន់ណារ៉ា | អគ្គនាយករងអយ្យការព្រហ្មទណ្ឌ | ក្រសួងយុត្តិធម៌ |
| - ឧត្តមសេនីយ៍ទោ | ជីវ ផល្លី | អនុប្រធាននាយកដ្ឋាន | អគ្គស្នងការដ្ឋាននគរបាលជាតិ |
| - ឧត្តមសេនីយ៍ត្រី | គីម ភាព | អនុប្រធាននាយកដ្ឋាន | អគ្គស្នងការដ្ឋាននគរបាលជាតិ |
| - លោកស្រី | កែវ ម៉ាលី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| - លោក | ទេព ស៊ីមន | អនុប្រធានការិយាល័យ | ក្រសួងកិច្ចការនារី |
| - លោក | នុត សំអុល | មន្ត្រីគម្រោង | IOM |
| - លោក | លឹម ទិត្យ | អ្នកសម្របសម្រួល | UN-ACT |
| - ឧត្តមសេនីយ៍ទោ | ញឹម សំបួន | នាយករងទីចាត់ការការងារព្រំដែន | អគ្គបញ្ជាការដ្ឋាន |
| - ឧត្តមសេនីយ៍ត្រី | ជិន ពិសិដ្ឋ | នាយករងទីចាត់ការការងារព្រំដែន | អគ្គបញ្ជាការដ្ឋាន |
| - វរសេនីយ៍ឯក | ឌី ដាម៉ង់ | អនុប្រធានច្រកទ្វារទី១ | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| - វរសេនីយ៍ត្រី | ឧច សុវណ្ណឧត្តម | អនុប្រធាននាយកដ្ឋានរដ្ឋបាលសរុប | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| - វរសេនីយ៍ទោ | សោម វណ្ណេត | នាយរងការិយាល័យ | កងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| - លោក | សេង សូវ៉ាត | អនុប្រធានការិយាល័យ | ក្រសួងអប់រំយុវជន និងកីឡា |
| - លោកស្រី | រាម នាវតី | ប្រធានការិយាល័យ | ក្រសួងយុត្តិធម៌ |

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

| | | | |
|---|---|---|---|
| - លោក | អៀម សំណាង | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ក្រសួងយុត្តិធម៌ |
| - លោក | អ៊ុន វុទ្ធី | អ្នកជំនាញផ្នែកការពារជនរងគ្រោះ | WI ( Winrock International ) |
| - លោក | ជុំ ផល្លី | ទីប្រឹក្សា | WINROCK |
| - លោក | ញ៉ែម ទូច | មន្ត្រីតាមដាននិងវាយតម្លៃ | Cambodia ACTs |
| - លោក | ហួន ទីម | ប្រធានផ្នែកស៊ើបអង្កេត | APLE |
| - លោកស្រី | ឃ្លោក កញ្ញា | មន្ត្រីសង្គមកិច្ច | IOM |